00384761

E64/2

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 05 / 10 / 2009
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ការដាក់តម្កល់ឯកសារ**

**សំណុំរឿងលេខ៖** ០០១/១៨-០៧-២០០៧-អ.វ.ត.ក(អ.ជ.ស.ដ)

**ភាគីអ្នកតម្កល់៖** សហមេធាវីរបស់លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច

**ដាក់តម្កល់ជូន៖** អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម៖** ភាសាបារាំង

**កាលបរិច្ឆេទដាក់ឯកសារ៖** ០២ តុលា ២០០៩

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ស្នើដោយភាគីអ្នកដាក់តម្កល់៖ **សាធារណៈ**

ចំណាត់ថ្នាក់សម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖

លក្ខន្តិកៈនៃចំណាត់ថ្នាក់៖

ការពិនិត្យចំណាត់ថ្នាក់បណ្តោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿងនិងឯកសារ៖

ហត្ថលេខា៖

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 10 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

# សេចក្តីកត់សម្គាល់របស់ក្រុមការពារក្តី លើសេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងឯកសារស្តីពីជម្លោះប្រដាប់អាវុធ និងលើសំណើរបស់ក្រុមការពារក្តីទាក់ទងនឹងសេចក្តីប្រកាសរបស់ជនត្រូវចោទនៅក្នុង សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក-កសចស

---

| **បញ្ជូនដោយ៖** | **បញ្ជូនទៅ៖** | **ចម្លងជូន៖** |
|---|---|---|
| **មេធាវីរបស់ជនជាប់ចោទ** | **ចៅក្រមអង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| **លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច** | លោកចៅក្រម និល ណុន (ប្រធាន) | លោកស្រី ជា លាង |
| មេធាវី ការ សាវុត្ត | លោកស្រីចៅក្រម Silvia CARTWRIGHT | លោក Robert PETIT |

00384762



E61/2

មេធាវី François ROUX

លោកចៅក្រម យ៉ា សុខន

លោកចៅក្រម Jean-Marc LAVERGNE

លោកចៅក្រម ធូ មណី

ចម្លងជូន៖

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

លោកមេធាវី គង់ ពិសី

លោកមេធាវី ហុង គឹមសួន

លោកមេធាវី យុង ផានិត

លោកមេធាវី គីម ម៉េងឃី

កញ្ញាមេធាវី ម៉ុច សុវណ្ណារី

កញ្ញាមេធាវី ទី្រ ស្រីនណា

លោកស្រីមេធាវី Silke STUDZINSKY

លោកស្រីមេធាវី Martine JACQUIN

លោកមេធាវី Philippe CANNONE

លោកមេធាវី Pierre Olivier SUR

លោកមេធាវី Alain WERNER

លោកមេធាវី Brianne McGONIGLE

លោកស្រីមេធាវី Annie DELAHAIE

លោកស្រីមេធាវី Elizabeth RABESANDRATANA

លោកមេធាវី Karim KHAN

លោកស្រី Fabienne TRUSSES-NAPROUS

លោកស្រីមេធាវី Christine MARTINEAU

[០០១/១៨-០៧-២០០៧-អវតក/អជសង]

E61/2

## សូមគោរពជូនអង្គជំនុំជម្រះសាលាដំបូង

១- ក្រោយពីបានពិនិត្យឯកសារដែលមានចំណងជើងថា "សេចក្តីសង្ខេបរបស់ការិយាល័យសហព្រះរាជអាជ្ញា ទាក់ទិននឹងឯកសារស្តីពីជម្លោះប្រដាប់អាវុធ ដែលបានដាក់ភ្ជាប់ជាមួយនឹងញត្តិចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩" (ឯកសារ E61/1.1) មក មេធាវីការពារក្តី សូមបង្ហាញសេចក្តីកត់សម្គាល់ និងដាក់សំណើមួយ ដូចខាងក្រោម។

២- ក្រុមការពារក្តីកត់សម្គាល់ឃើញថា "សេចក្តីសង្ខេប"ឯកសារមួយស្តីពីជម្លោះប្រដាប់អាវុធ ដែលបានដាក់ដោយការិយាល័យសហព្រះរាជអាជ្ញា ជាទូទៅ មិនមានលក្ខណៈសត្យានុម័តិទេ ព្រោះថា ការវិភាគគតិយុត្តិរបស់ការិយាល័យសហព្រះរាជអាជ្ញាផ្ទាល់លើឯកសារចំនួន៤៣០ ស្តីពីជម្លោះប្រដាប់អាវុធ ដែលបានលើកឡើងនៅក្នុងឯកសារមួយនេះ ដូចដែលខ្លួនបានបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូងរួចមកហើយនោះ មិនមានលក្ខណៈត្រឹមត្រូវទេ។

៣- ជាឧទាហរណ៍ នៅក្នុងកថាខណ្ឌទី៤ នៃឯកសារនេះ សហព្រះរាជអាជ្ញាបានអះអាងថា "ឯកសារទាំង៤៣០នោះ បង្ហាញនូវកាលប្បវត្តិមួយនៃអំពើហិង្សានានា ដែលបានកើតមានជាហូរហែ និងដោយអូសបន្លាយយ៉ាងយូរ នៅប្រទេសកម្ពុជា និងវៀតណាម"។ ដោយប្រើប្រាស់ពាក្យថា "ជាហូរហែ និងអូសបន្លាយយ៉ាងយូរ"នោះ សហព្រះរាជអាជ្ញាបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង នូវការវិភាគផ្ទាល់របស់ខ្លួនលើបណ្តាឯកសារនានា តែមិនបានធ្វើការបង្ហាញបែបសត្យានុម័តិពីឯកសារទាំងនោះទេ ហើយថែមទាំងព្យាយាមជះឥទ្ធិពលទៅលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះលើបញ្ហានេះទៀតផង។

៤- សម្រាប់ពេលនេះ ក្រុមការពារក្តីមិនជំទាស់ទៅនឹងសេចក្តីសង្ខេប "អត្ថបទ និងសេចក្តីប្រកាសព័ត៌មាន" ចំនួន២២៣ (សៀវភៅលេខ២) ដែលរៀបរៀងឡើងជាភាសាបារាំងនិងខ្មែរ និងទទួលខុសត្រូវដោយការិយាល័យសហព្រះរាជអាជ្ញានោះទេ។ ដូចគ្នានេះដែរ ក្រុម

ការពារក្តីក៏មិនជំទាស់ទៅនឹងសេចក្តីសង្ខេបនានាលើឯកសារនៅក្នុងសៀវភៅទី១ និងទី៣ ដែរ លើកលែងតែ "សេចក្តីប្រកាសរបស់ជនសង្ស័យ" ចំនួន៩ ដែលបានបង្ហាញនៅក្នុងសៀវភៅទី១ ផ្នែកទី៤។

៥- ក្រុមការពារក្តីជំទាស់ដាច់ខាតទៅនឹងការិយាល័យសហព្រះរាជអាជ្ញា ដែលប្រើប្រាស់សេចក្តីប្រកាសខាងលើនេះ នៅក្នុងសំណុំរឿង០០១នេះ ខណៈដែលសេចក្តីប្រកាសនេះទទួលបានមកពីជនត្រូវចោទនៅក្នុងសំណុំរឿង០០២/១៩-០៩-២០០៧/អវតក/កសចស ទៅវិញនោះ។

៦- ការប្រើប្រាស់សេចក្តីប្រកាសទាំងនេះរបស់ការិយាល័យសហព្រះរាជអាជ្ញា នឹងក្លាយទៅជាការបង្វែងដានទីតិវិធីមួយ ដែលបង្កឡើងដោយការិយាល័យនេះ ព្រមទាំងរំលោភទៅលើសិទ្ធិជនត្រូវចោទនៅក្នុងសំណុំរឿងលេខ០០២ ផង។ អាស្រ័យហេតុនេះ ក្រុមការពារក្តីស្នើសុំកុំដាក់បញ្ចូលសេចក្តីប្រកាសរបស់ជនត្រូវចោទទាំងនេះ ទៅក្នុងកិច្ចពិភាក្សានានានៅក្នុងសំណុំរឿងនេះ។

៧- ជាទីបញ្ចប់ ក្រុមការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យមើលជំហររបស់ខ្លួននៅក្នុងអំឡុងពេលនៃកិច្ចពិភាក្សាស្តីពីជម្លោះប្រដាប់អាវុធឡើងវិញ។

**តាមរយៈហេតុផលទាំងនេះ**

៨- ក្រុមការពារក្តីសូមស្នើទៅអង្គជំនុំជម្រះសាលាដំបូង មេត្តា៖

- **បដិសេធចោល** សំណើរបស់សហព្រះរាជអាជ្ញាដែលមានបំណងដាក់បញ្ចូលសេចក្តីប្រកាសរបស់ជនត្រូវចោទនៅក្នុងរឿងសំណុំរឿង០០២/១៩-០៩-២០០៧/អវតក/កសចស ទៅក្នុងកិច្ចពិភាក្សា។

**សូមរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង**

| | | | |
|---|---|---|---|
| 02-10-2009 | សហមេធាវីការពារក្ដី<br>មេធាវី **ការ សាវុត្ថ** | ភ្នំពេញ | [signature] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |